ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

លេខ......១៥០.........បទ.ប្រក..............

# ប្រកាស
# ស្តីពី
# បែបបទ និងនីតិវិធី នៃការធ្វើអធិការកិច្ចក្នុងវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៧ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០០៩ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៧ ប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ១៨៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ១១០ អនក្រ.បក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការផ្តល់ការអនុញ្ញាតឱ្យបំពេញប្រតិបត្តិការលើវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- យោងតាមការចាំបាច់របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.**

ប្រកាសនេះមានគោលបំណង កំណត់នូវបែបបទ និងនីតិវិធី នៃការធ្វើអធិការកិច្ចក្នុងវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២.**

ប្រកាសនេះមានគោលដៅដូចតទៅ៖

ក - កំណត់អំពីក្របខណ្ឌសមត្ថកិច្ចអនុវត្តការធ្វើអធិការកិច្ចនៅតាមទីតាំងផលិតកម្ម អាជីវកម្ម សេវាកម្ម ឬសម្រាប់ធ្វើសកម្មភាពផ្សេងទៀតពាក់ព័ន្ធវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

ខ - កំណត់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់ប្រតិបត្តិករ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

គ - កំណត់អំពីនីតិវិធីសម្រាប់អនុវត្តនៅក្នុងដំណើរការនៃការធ្វើអធិការកិច្ចនៅតាមទីតាំងផលិតកម្ម អាជីវកម្ម សេវាកម្ម ឬសកម្មភាពពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

ឃ - ជំរុញការចូលរួមពីប្រតិបត្តិករ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន និងគ្រប់ភាគីពាក់ព័ន្ធក្នុងការអនុវត្តច្បាប់ និងវិធានការទប់ស្កាត់ និងការកាត់បន្ថយការប្រព្រឹត្តអំពើខុសច្បាប់ និងបទល្មើសក្នុងវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។

**ប្រការ ៣.**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះការធ្វើអធិការកិច្ច និងរាល់ប្រតិបត្តិការជំរុញការអនុវត្តច្បាប់លើគ្រប់គ្រឹះស្ថាន និងគ្រប់សកម្មភាពដែលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី ២

## អង្គភាពមានសមត្ថកិច្ច និងមន្ត្រីអធិការកិច្ចទូរគមនាគមន៍

**ប្រការ ៤.**

អគ្គាធិការដ្ឋាន នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ជាអង្គភាពមានសមត្ថកិច្ចក្នុងការដឹកនាំការធ្វើអធិការកិច្ចក្នុងវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។

ការចុះធ្វើអធិការកិច្ចក្នុងវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានត្រូវអនុវត្តដោយមន្ត្រីអធិការកិច្ចទូរគមនាគមន៍។

**ប្រការ ៥.-**

មន្ត្រីអធិការកិច្ចទូរគមនាគមន៍ ត្រូវជាមន្ត្រីដែលទទួលបានការផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌ដោយអនុលោមតាមប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

**ប្រការ ៦.-**

មន្ត្រីអធិការកិច្ចទូរគមនាគមន៍ មានភារកិច្ច និងសិទ្ធិដូចខាងក្រោម៖

ក - ទទួលពាក្យបណ្តឹង ឬពាក្យស្នើសុំពាក់ព័ន្ធនឹងការធ្វើអធិការកិច្ចក្នុងវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

ខ - ធ្វើអធិការកិច្ចបច្ចេកទេសលើគ្រឿងសម្ភារបរិក្ខារ ហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញ និងការផ្តល់សេវាទូរគមនាគមន៍ និង/ឬសេវាបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

គ - ស្រាវជ្រាវ អង្កេត តាមដាន ទប់ស្កាត់ និងបង្ក្រាបបទល្មើសក្នុងវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

ឃ - ត្រួតពិនិត្យជាប្រចាំលើរាល់សកម្មភាពរបស់ប្រតិបត្តិករ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

ង - តម្រូវឱ្យប្រតិបត្តិករ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ធ្វើការផ្តល់ព័ត៌មាននិងបង្ហាញនូវលិខិតអនុញ្ញាត វិញ្ញាបនបត្រ អាជ្ញាបណ្ណ និង/ឬឯកសារផ្សេងទៀតពាក់ព័ន្ធនឹងការបំពេញប្រតិបត្តិការក្នុងវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

ច - ស្នើសុំរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងអង្គភាពមានសមត្ថកិច្ចផ្សេងទៀត ដើម្បីចាត់វិធានការសមស្របទៅលើប្រតិបត្តិករ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន និងគ្រប់បុគ្គលស្របតាមការកំណត់របស់ច្បាប់ស្តីពីទូរគមនាគមន៍ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន

ឆ - ដកយកសំណាកទិន្នន័យនិងគ្រឿងសម្ភារបរិក្ខារដែលជាកម្មវត្ថុ នៃការត្រួតពិនិត្យស្តង់ដា និងមុខងារគ្រឿងសម្ភារបរិក្ខារពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន និងធ្វើការវិភាគផ្ទៀងផ្ទាត់បរិមាណសេវាទូរគមនាគមន៍ និងសេវាបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

ជ - ចាប់យកវត្ថុតាង និងបិទស្លាកបោះត្រាលើវត្ថុតាង

ឈ- ធ្វើកំណត់ហេតុត្រួតពិនិត្យកន្លែងកើតហេតុនៅរាល់ពេលធ្វើប្រតិបត្តិការអធិការកិច្ច និងបំពេញសំណុំបែបបទ ផ្សេងទៀតដោយអនុលោមតាមគំរូសំណុំបែបបទប្រើប្រាស់ក្នុងការធ្វើអធិការកិច្ច និងដោះស្រាយបទល្មើសពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

ញ - បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

**ប្រការ ៧.-**

នៅក្នុងប្រតិបត្តិការធ្វើអធិការកិច្ច មន្ត្រីអធិការកិច្ចទូរគមនាគមន៍មិនត្រូវ៖

ក - ជ្រៀតជ្រែកក្នុងដំណើរការ ឬប្រតិបត្តិការរបស់ប្រតិបត្តិករ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានឡើយ

ខ - បង្កឱ្យមានការប៉ះពាល់ដល់ដំណើរការ ឬប្រតិបត្តិការរបស់ប្រតិបត្តិករ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ដែលបណ្តាលមកពីសកម្មភាពមិនអនុលោមតាមច្បាប់ និងនីតិវិធីជាធរមានណាមួយនៅក្នុងប្រតិបត្តិការអធិការកិច្ចរបស់ខ្លួន

គ - បញ្ចេញជាសាធារណៈនូវព័ត៌មានសម្ងាត់របស់ប្រតិបត្តិករ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន លើកលែងតែមានការអនុញ្ញាតពីច្បាប់ និងអាជ្ញាធរធម្មានុរូប។

## ជំពូកទី ៣
## សិទ្ធិ និងកាតព្វកិច្ចរបស់ប្រតិបត្តិករនិងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

### ប្រការ ៨.-

នៅពេលមានប្រតិបត្តិការធ្វើអធិការកិច្ចរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍ ប្រតិបត្តិករ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានមានសិទ្ធិ និងកាតព្វកិច្ចដូចខាងក្រោម៖

ក - អាចស្នើសុំមន្ត្រីអធិការកិច្ចទូរគមនាគមន៍ ឱ្យបង្ហាញលិខិតបញ្ជាបេសកកម្ម និង/ឬលិខិតឧទ្ទេសនាម

ខ - ត្រូវអនុញ្ញាតឱ្យមន្ត្រីអធិការកិច្ចទូរគមនាគមន៍ចូលត្រួតពិនិត្យ និងផ្តល់កិច្ចសហការក្នុងការធ្វើអធិការកិច្ច ដូចមានចែងនៅក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន

គ - ត្រូវចូលរួមជានិច្ចជាមួយមន្ត្រីអធិការកិច្ចទូរគមនាគមន៍ នៅពេលមានការធ្វើអធិការកិច្ចក្នុងទីតាំងផលិតកម្ម អាជីវកម្ម សេវាកម្ម ឬសម្រាប់ធ្វើសកម្មភាពផ្សេងទៀតពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានរបស់ខ្លួន

ឃ - ត្រូវឆ្លើយបំភ្លឺ ពន្យល់ ផ្តល់ព័ត៌មាននិងឯកសារ ឬផ្តល់សេចក្តីអះអាងពាក់ព័ន្ធនឹងការគោរព និងការអនុវត្តច្បាប់ប្រកបដោយសីលធម៌ សុចរិតភាព និងការទទួលខុសត្រូវ

ង - ត្រូវបំពេញ ឬឆ្លើយតបនឹងបញ្ជីសំណួររបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍ និងត្រូវផ្តល់សំណាកផ្សេងៗ ដែលជាកម្មវត្ថុ នៃការត្រួតពិនិត្យ និងការធ្វើវិភាគផ្ទៀងផ្ទាត់

ច - ស្នើសុំឲ្យមន្ត្រីអធិការកិច្ចទូរគមនាគមន៍ កត់ត្រានូវរាល់ការឆ្លើយតប ឬសេចក្តីអះអាងទាំងនោះនៅក្នុងកំណត់ហេតុត្រួតពិនិត្យ និងមានសិទ្ធិទទួលបាននូវកំណត់ហេតុ ឬរបាយការណ៍លទ្ធផលនៃការធ្វើអធិការកិច្ច

ឆ - ត្រូវធ្វើការកែតម្រូវចំពោះបដិលោមភាព នៃបច្ចេកទេស និងនីតិវិធីអនុវត្តនៅក្នុងប្រតិបត្តិការលើវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

ជ - អាចធ្វើការជំទាស់ ឬតវ៉ាចំពោះសកម្មភាពមិនស្របច្បាប់ណាមួយ ដែលប្រព្រឹត្តដោយមន្ត្រីអធិការកិច្ចទូរគមនាគមន៍

ឈ- ត្រូវបំពេញកាតព្វកិច្ចផ្សេងទៀតក្នុងក្របខណ្ឌ នៃការធ្វើអធិការកិច្ចក្នុងវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។

**ប្រការ ៩.**

ប្រតិបត្តិករ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានដែលត្រូវបានរកឃើញថាមានកំហុស ឬប្រព្រឹត្តនូវបទល្មើសដែលតម្រូវឱ្យមានការធ្វើអធិការកិច្ច ត្រូវទទួលបន្ទុកក្នុងការចំណាយទាំងស្រុងលើដំណើរការ នៃការធ្វើអធិការកិច្ចរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍។

ក្នុងករណីមានពាក្យបណ្ដឹង ឬពាក្យស្នើសុំឱ្យធ្វើអធិការកិច្ចលើប្រតិបត្តិករ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានណាមួយ ប្រសិនបើរកឃើញថាប្រតិបត្តិករនិងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ដែលស្ថិតក្នុងការធ្វើអធិការកិច្ចមិនមានកំហុសទេ បន្ទុកចំណាយទាំងស្រុងលើដំណើរការ នៃការធ្វើអធិការកិច្ចរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍ត្រូវធ្លាក់ទៅលើបុគ្គលដែលបានដាក់ពាក្យបណ្ដឹង ឬពាក្យស្នើសុំនោះ។

ការចំណាយលើការអនុវត្តច្បាប់ និងបទប្បញ្ញត្តិជាធរមាន គឺជាបន្ទុករបស់រដ្ឋ។

## ជំពូកទី ៤
## នីតិវិធី នៃការធ្វើអធិការកិច្ចក្នុងវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

**ប្រការ ១០.**

មន្ត្រីអធិការកិច្ចទូរគមនាគមន៍ មានសិទ្ធិធ្វើអធិការកិច្ចតាមកាលកំណត់ ឬមិនតាមកាលកំណត់ ដោយមានការជូនដំណឹងជាមុន ឬដោយពុំមានការជូនដំណឹងជាមុនដល់ប្រតិបត្តិករ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។

ក្នុងករណីធ្វើអធិការកិច្ចដោយមានការជូនដំណឹងជាមុន សេចក្ដីជូនដំណឹងផ្លូវការត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍តាមសំណើរសុំរបស់អគ្គាធិការនៃអគ្គាធិការដ្ឋាន ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ហើយត្រូវជូនដំណឹងដល់ប្រតិបត្តិករ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានដោយរក្សាទុកពេលវេលាសមស្រប ដើម្បីឱ្យប្រតិបត្តិករ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាននោះត្រៀមលក្ខណៈសម្រាប់ការចុះធ្វើអធិការកិច្ច។ សេចក្ដីជូនដំណឹងផ្លូវការនេះត្រូវធ្វើជូនក្នុងរយៈពេលមិនតិចជាង៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការមុនថ្ងៃធ្វើអធិការកិច្ច។

ការធ្វើអធិការកិច្ចដោយពុំមានការជូនដំណឹងជាមុន ត្រូវអនុវត្តចំពោះតែៈ

ក - ករណីស្រាវជ្រាវឃើញមានបទល្មើសជាក់ស្ដែងពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។

ខ - ករណីត្រួតពិនិត្យឃើញថាមានប្រតិបត្តិការទូរគមនាគមន៍ ឬប្រតិបត្តិការបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន មុនពេលទទួលបានការអនុញ្ញាតឱ្យបំពេញប្រតិបត្តិការដោយស្ថាប័នមានសមត្ថកិច្ច។

**ប្រការ ១១.**

នៅរាល់ពេលធ្វើអធិការកិច្ច មន្ត្រីអធិការកិច្ចទូរគមនាគមន៍ ត្រូវមានលិខិតបញ្ជាបេសកកម្ម និង / ឬ លិខិត

ឧទ្ទេសនាម ហើយត្រូវមានឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍ឱ្យបានត្រឹមត្រូវ។

គំរូសេចក្តីជូនដំណឹង ស្តីពីការធ្វើអធិការកិច្ចក្នុងវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធ នៃប្រកាសនេះ។

**ប្រការ ១២.**

នៅក្នុងប្រតិបត្តិការអធិការកិច្ច មន្ត្រីអធិការកិច្ចទូរគមនាគមន៍ត្រូវអនុវត្តតាមនីតិវិធី ដូចខាងក្រោម៖

**១.នីតិវិធីក្នុងដំណាក់កាលត្រៀមអធិការកិច្ច**

នៅមុនពេលចុះប្រតិបត្តិការធ្វើអធិការកិច្ច មន្ត្រីអធិការកិច្ចទូរគមនាគមន៍ ត្រូវត្រៀមលក្ខណៈដូចខាងក្រោម៖

ក - យកជាប់ជាមួយនូវឯកសាររួមមាន ច្បាប់ បទដ្ឋានគតិយុត្តពាក់ព័ន្ធ បញ្ជីសំណួរ សំណុំបែបបទ ដែលត្រូវប្រើប្រាស់ក្នុងការអនុវត្តច្បាប់ និងឯកសារចាំបាច់ផ្សេងទៀត

ខ - ទំនាក់ទំនង និងសហការជាមួយមន្ត្រី កងកម្លាំងប្រដាប់អាវុធ ឬអង្គភាពមានសមត្ថកិច្ចពាក់ព័ន្ធ នៅទីតាំងសម្រាប់ធ្វើអធិការកិច្ច

គ - ក្នុងករណីចាំបាច់ត្រូវជូនដំណឹង ឬទំនាក់ទំនងជាមុនជាមួយអាជ្ញាធរដែនដីដែលត្រូវចុះធ្វើអធិការកិច្ច ដើម្បីស្នើសុំកិច្ចសហការ។

**២.នីតិវិធីក្នុងដំណាក់កាលចាប់ផ្តើមអធិការកិច្ច**

នៅពេលចូលដល់ទីតាំងសម្រាប់ធ្វើអធិការកិច្ច ឬនៅទីកន្លែងកើតមានបទល្មើសមន្ត្រីអធិការកិច្ចទូរគមនាគមន៍ ត្រូវបង្ហាញលិខិតបញ្ជាបេសកកម្ម និង/ឬ លិខិតឧទ្ទេសនាម ត្រូវអានខ្លឹមសារលិខិតបញ្ជាបេសកកម្ម និងត្រូវពន្យល់ឱ្យបានច្បាស់លាស់ពីគោលបំណង ក្របខណ្ឌ និងវិសាលភាព នៃការធ្វើអធិការកិច្ចរបស់ខ្លួនស្របតាមនីតិវិធីនិងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**៣.នីតិវិធីក្នុងដំណាក់កាលត្រួតពិនិត្យជាក់ស្តែង**

មន្ត្រីអធិការកិច្ចទូរគមនាគមន៍ ត្រូវអនុវត្តនីតិវិធីដូចខាងក្រោម៖

ក - ត្រូវឱ្យតំណាងប្រតិបត្តិករ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន បង្ហាញនូវសៀវភៅកំណត់ត្រាពាណិជ្ជកម្ម និងបង្ហាញនូវលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណដែលពាក់ព័ន្ធនឹងប្រតិបត្តិការរបស់ខ្លួន

ខ - ត្រូវឱ្យតំណាងប្រតិបត្តិករ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន បង្ហាញនូវវិក្កយបត្រ ឯកសារសេក្តីបត្រ ឬឯកសារពាក់ព័ន្ធនឹងប្រតិបត្តិការ ដោយត្រូវប្រើបញ្ជីសំណួរដែលបានរៀបចំជាមុន សម្រាប់ប្រើប្រាស់ក្នុងការធ្វើអធិការកិច្ច

គ - ត្រូវត្រួតពិនិត្យលើការអនុវត្តច្បាប់ បច្ចេកទេស ហិរញ្ញវត្ថុ បុគ្គលិក និងដកយកសំណាកសម្រាប់ធ្វើវិភាគ ថតរូបសកម្មភាពធ្វើអធិការកិច្ចរបស់ខ្លួន និងត្រូវប្រមូល ឬថតចម្លងឯកសារពាក់ព័ន្ធដែលចាំបាច់ដើម្បីទុកជាភស្តុតាង នៃសំណុំរឿងបទល្មើស ឬភ្ជាប់ក្នុងរបាយការណ៍

ឃ - ត្រូវចាត់វិធានការតាមច្បាប់ ចំពោះបុគ្គលប្រព្រឹត្តបទល្មើសស្របតាមវិធានការពាក់ព័ន្ធដូចមានចែងក្នុងប្រការ១៦ នៃប្រកាសនេះ។

**៤.នីតិវិធីក្នុងដំណាក់កាលបញ្ចប់អធិការកិច្ច**

នៅពេលបញ្ចប់ការត្រួតពិនិត្យជាក់ស្តែង មន្ត្រីអធិការកិច្ចទូរគមនាគមន៍ ត្រូវអនុវត្តនីតិវិធីដូចខាងក្រោម៖

ក - បូកសរុបបញ្ចប់លទ្ធផល នៃការធ្វើអធិការកិច្ច រៀបចំកំណត់ហេតុ ព្រមទាំងបំពេញសំណុំបែបបទពាក់ព័ន្ធផ្សេងទៀតតាមករណីជាក់ស្តែង

ខ - បង្ហាញដល់ប្រតិបត្តិករ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន នូវកំហុសរបស់ខ្លួនក្នុងការធ្វើប្រតិបត្តិការ ដែលមន្ត្រីអធិការកិច្ចទូរគមនាគមន៍ បានត្រួតពិនិត្យរកឃើញដោយត្រូវណែនាំដល់ប្រតិបត្តិករ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានឱ្យអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន

គ - ចុះហត្ថលេខាលើកំណត់ហេតុ និងលើសំណុំបែបបទផ្សេងទៀត ដោយត្រូវអានកំណត់ហេតុនោះឱ្យដល់តំណាងប្រតិបត្តិករ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានបានស្តាប់ឮដោយផ្ទាល់ដើម្បីឱ្យបុគ្គលនោះយល់ព្រមចុះហត្ថលេខាលើកំណត់ហេតុ ឬ សំណុំបែបបទ នៃការធ្វើអធិការកិច្ច។

**៥.នីតិវិធីក្នុងដំណាក់កាលក្រោយបញ្ចប់អធិការកិច្ច**

មន្ត្រីអធិការកិច្ចទូរគមនាគមន៍ ត្រូវធ្វើរបាយការណ៍អធិការកិច្ចជាលាយលក្ខណ៍អក្សរជូនអគ្គាធិការ នៃអគ្គាធិការដ្ឋាន ក្នុងរយៈពេលយ៉ាងយូរ១០ (ដប់)ថ្ងៃនៃថ្ងៃធ្វើការ ដោយគិតចាប់ពីថ្ងៃបញ្ចប់ការងារអធិការកិច្ច។ ក្នុងករណីចាំបាច់ មន្ត្រីអធិការកិច្ចទូរគមនាគមន៍ អាចធ្វើរបាយការណ៍ផ្ទាល់មាត់ជាមុនតាមការតម្រូវរបស់អគ្គាធិការ នៃអគ្គាធិការដ្ឋាន។

របាយការណ៍អធិការកិច្ចក្នុងវិស័យទូរគមនាគមន៍និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានត្រូវមានខ្លឹមសារអប្បបរមាស្របតាមមាតិកាដូចខាងក្រោម៖

ក - យោងលិខិតបញ្ជាបេសកកម្ម និង/ឬ លិខិតឧទ្ទេសនាមដែលបញ្ជាក់សមាសភាពក្រុមមន្ត្រីអធិការកិច្ច

ខ - សមាសភាពអ្នកចូលរួមដទៃទៀត

គ - គោលបំណង នៃការធ្វើអធិការកិច្ច

ឃ- ទីកន្លែងធ្វើអធិការកិច្ច

ង - លទ្ធផល នៃការធ្វើអធិការកិច្ច

ច - វិធានការរបស់មន្ត្រីអធិការកិច្ចនៅនឹងកន្លែងកើតហេតុ

ឆ - ការចងក្រងសំណុំរឿង

ជ - ការស្នើសុំវិធានការបន្តពីអគ្គាធិការនៃអគ្គាធិការដ្ឋាន ឬស្នើសុំសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍-

ឈ-ត្រូវភ្ជាប់ឯកសារពាក់ព័ន្ធជាអាទិ៍ រូបថតសកម្មភាព ឬកស្តុតាងចាំបាច់ផ្សេងទៀត។

**ប្រការ ១៣..**

ការធ្វើអធិការកិច្ចបន្តជាថ្មីម្តងទៀត នឹងត្រូវអនុញ្ញាតឱ្យមន្ត្រីអធិការកិច្ចទូរគមនាគមន៍ ដោយពុំចាំបាច់មានការជូនដំណឹងជាមុន ឬការចុះត្រួតពិនិត្យការអនុវត្តរបស់ប្រតិបត្តិករឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ និង

វិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានលើចំណុចដែលបានទទួលការព្រមានឱ្យកែតម្រូវ ឬការដាក់ទណ្ឌកម្មផ្សេងទៀត ដើម្បីធានានូវការអនុវត្តត្រឹមត្រូវតាមវិធានការដែលបានដាក់ចេញនៅពេលធ្វើអធិការកិច្ចលើកមុន។

**ប្រការ ១៤.-**

មន្ត្រីអធិការកិច្ចទូរគមនាគមន៍ ត្រូវគ្រប់គ្រងឯកសារនៃសំណុំរឿងនីមួយៗ ដោយត្រូវរៀបចំ និងកត់ត្រានៅក្នុងសៀវភៅកំណត់ត្រាតាមដានសំណុំរឿង ដែលជាឯកសារមូលដ្ឋានប្រើប្រាស់សម្រាប់ការគ្រប់គ្រងការងារធ្វើអធិការកិច្ច និងការអនុវត្តច្បាប់ ដោយត្រូវកត់ត្រានូវព័ត៌មាន និងទិន្នន័យសំខាន់ៗតាមករណីនីមួយៗ ចាប់ពីដំណាក់កាលធ្វើអធិការកិច្ចបឋមរហូតដល់ករណីនោះត្រូវបានដោះស្រាយរួចជាស្ថាពរតាមនីតិវិធី។

## ជំពូកទី ៥
## វិធានការរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍

**ប្រការ ១៥.-**

រាល់ប្រតិបត្តិការអធិការកិច្ច មន្ត្រីអធិការកិច្ចទូរគមនាគមន៍ត្រូវអនុវត្តតាមបទប្បញ្ញត្តិ នៃប្រកាសនេះ និងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

មន្ត្រីអធិការកិច្ចទូរគមនាគមន៍ អាចស្នើសុំជំនួយពីអាជ្ញាធរដែនដីគ្រប់ថ្នាក់ និងអង្គភាពប្រដាប់អាវុធឬអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមសហការធ្វើអធិការកិច្ច ដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ ១៦.-**

នៅក្នុងដំណើរការអធិការកិច្ចក្នុងវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានក្នុងករណីជួបបទល្មើសជាក់ស្តែង មន្ត្រីអធិការកិច្ចទូរគមនាគមន៍ មានសិទ្ធិដកហូតជាបណ្តោះអាសន្ននូវលិខិតអនុញ្ញាត វិញ្ញាបនបត្រ អាជ្ញាបណ្ណគ្រប់ប្រភេទ ឬឯកសារដែលពាក់ព័ន្ធដើម្បីវិភាគផ្ទៀងផ្ទាត់ រួមទាំងចាប់យកវត្ថុតាងនិងបិទស្លាកបោះត្រាលើវត្ថុតាង។ ក្នុងករណីនេះ មន្ត្រីអធិការកិច្ចទូរគមនាគមន៍ត្រូវរាយការណ៍ជាបន្ទាន់មកអគ្គាធិការ នៃអគ្គាធិការដ្ឋាន ដើម្បីស្នើសុំគោលការណ៍ណែនាំពីរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ដើម្បីចាត់វិធានការសមស្រប ដូចមានកំណត់ក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ ១៧.-**

ដោយផ្អែកតាមរបាយការណ៍អធិការកិច្ចរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍ និងសំណុំរឿងក្នុងរយៈពេលមិនលើសពី១៥ (ដប់ប្រាំ) ថ្ងៃគិតចាប់ពីថ្ងៃទទួលរបាយការណ៍ អគ្គាធិការ នៃអគ្គាធិការដ្ឋាន ត្រូវស្នើសុំការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ដើម្បីបញ្ឈប់ប្រតិបត្តិការរបស់ប្រតិបត្តិករ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ឬបញ្ជូនសំណុំរឿងទៅតុលាការមានសមត្ថកិច្ច ដើម្បីចាត់ការតាមនីតិវិធីច្បាប់។

**ប្រការ ១៨.-**

អគ្គាធិការ នៃអគ្គាធិការដ្ឋាន មានសិទ្ធិចេញលិខិតកោះហៅ ឬសេចក្តីជូនដំណឹងដល់ប្រតិបត្តិករ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ឬបុគ្គលដែលប្រព្រឹត្តផ្ទុយនឹងការកំណត់របស់ច្បាប់ និងបទប្បញ្ញត្តិជាធរមាន ដើម្បីចូលខ្លួនមកកាន់អង្គភាពមានសមត្ថកិច្ច ធ្វើការដោះស្រាយស្រប

តាមនីតិវិធីនៅក្នុងរយៈពេលជាកំណត់ជាក់លាក់។

ក្នុងករណីប្រតិបត្តិករ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ឬ បុគ្គលដែលប្រព្រឹត្តផ្ទុយនឹងការកំណត់របស់ច្បាប់ និងបទប្បញ្ញត្តិជាធរមានមិនបានចូលខ្លួនមកដោះស្រាយតាមកាលកំណត់ក្នុងលិខិតកោះហៅ ឬសេចក្តីជូនដំណឹង អគ្គាធិការ នៃអគ្គាធិការដ្ឋាន មានសិទ្ធិចាត់វិធានការបញ្ជូនសំណុំរឿងទៅតុលាការមានសមត្ថកិច្ចដើម្បីចាត់ការតាមនីតិវិធីច្បាប់បន្ទាប់ពីទទួលបានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

**ប្រការ ១៩.**

ប្រតិបត្តិករ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានណាដែលមិនសុខចិត្ត ចំពោះលទ្ធផលនៃការធ្វើអធិការកិច្ច ឬវិធានការណាមួយដែលកើតចេញពីការធ្វើអធិការកិច្ចអាចធ្វើបណ្តឹងតវ៉ាក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃគិតចាប់ពីថ្ងៃចេញវិធានការដើម្បីជូនរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ពិនិត្យ និងសម្រេច។

រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍អាចបង្កើតគណៈកម្មការស៊ើបអង្កេតមួយដើម្បីបើកការស្រាវជ្រាវ និងស៊ើបអង្កេតលើបណ្តឹងតវ៉ា។ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ត្រូវចេញសេចក្តីសម្រេចលើបណ្តឹងតវ៉ានោះក្នុងរយៈពេល ៤៥(សែសិបប្រាំ)ថ្ងៃយ៉ាងយូរគិតចាប់ពីថ្ងៃទទួលបណ្តឹង។

ក្នុងករណីប្រតិបត្តិករ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន នោះនៅតែមិនសុខចិត្តចំពោះសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បុគ្គលនោះមានសិទ្ធិធ្វើបណ្តឹងទៅយន្តការផ្សេងទៀតរបស់រាជរដ្ឋាភិបាល ឬធ្វើបណ្តឹងទៅតុលាការមានសមត្ថកិច្ចស្របតាមបទប្បញ្ញត្តិជាធរមាន។

**ប្រការ ២០.**

នៅក្នុងប្រតិបត្តិការអធិការកិច្ចក្នុងវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានមានតម្រូវការក្នុងការឆែកឆេរទីតាំងប្រតិបត្តិការរបស់ប្រតិបត្តិករ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន លំនៅឋាន គ្រឹះស្ថាន ឬមូលដ្ឋានធ្វើប្រតិបត្តិការផ្សេងទៀតដែលកើតមានអំពើល្មើសពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន មន្ត្រីអធិការកិច្ចទូរគមនាគមន៍ ត្រូវអនុវត្តវិធានការដូចខាងក្រោម៖

ក - ស្នើសុំដីកាឆែកឆេរពីសាលាដំបូងរាជធានី-ខេត្តសាមី ឬត្រូវមានបញ្ជាផ្ទាល់ពីព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងសាមី។ ក្នុងករណីចាំបាច់ត្រូវមានវត្តមានរបស់ព្រះរាជអាជ្ញាដើម្បីដឹកនាំនីតិវិធី និងត្រូវមានអាជ្ញាធរមូលដ្ឋាននៅកន្លែងកើតហេតុ ឬកម្លាំងប្រដាប់អាវុធ ចូលរួមតាមការចាំបាច់ក្នុងប្រតិបត្តិការឆែកឆេរ

ខ - ប្រមូលនិងកត់ត្រាទុកជាបណ្តោះអាសន្ននូវវត្ថុតាង និងភស្តុតាងផ្សេងទៀតនៅកន្លែងកើតអំពើល្មើស និងដកយកសំណាកផ្សេងៗដើម្បីធ្វើការវិភាគ

គ - ត្រូវបំពេញសំណុំបែបបទ នៃអំពើល្មើសនៅកន្លែងកើតហេតុឱ្យបានគ្រប់គ្រាន់តាមនីតិវិធី

ឃ- ក្នុងករណីមានការឃាត់ខ្លួនជនសង្ស័យ ការនាំខ្លួន និងបញ្ជូនសំណុំឯកសារឃាត់ខ្លួនជនសង្ស័យត្រូវប្រគល់ជូនព្រះរាជអាជ្ញាក្នុងដែនសមត្ថកិច្ចសាមីដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២១..**

នៅពេលបញ្ចប់ប្រតិបត្តិការរបស់ខ្លួន មន្ត្រីអធិការកិច្ចទូរគមនាគមន៍ ត្រូវរៀបចំឯកសារ និងសំណុំបែបបទបន្ថែមដែលពាក់ព័ន្ធដូចជា កំណត់ហេតុ នៃអំពើល្មើស សាលាកបត្រទោសទណ្ឌ ឯកសារបញ្ជាក់លទ្ធផលវិភាគសំណាកវត្ថុតាង របាយការណ៍សំយោគ និងដីកាអមបញ្ជូន។

សំណុំបែបបទ នៃអំពើល្មើសដែលត្រូវបញ្ជូនទៅតុលាការ ត្រូវមានការសម្រេចពីរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ តាមការសម្របសម្រួលរបស់អគ្គាធិការ នៃអគ្គាធិការដ្ឋានដោយមានដីកាអមបញ្ជូនសំណុំរឿង។

**ប្រការ ២២..**

សំណាកដែលជាកម្មវត្ថុ នៃការត្រួតពិនិត្យ ឬជាវត្ថុតាងនៃអំពើល្មើសត្រូវបានដកយកដើម្បីធ្វើវិភាគ។ កញ្ចប់សំណាក ត្រូវបិទភ្ជិត ត្រូវមានស្លាកសម្គាល់ និងមានហត្ថលេខា នៃមន្ត្រីអធិការកិច្ចទូរគមនាគមន៍ ព្រះរាជអាជ្ញា ឬតំណាង និងបុគ្គលប្រព្រឹត្តអំពើល្មើសឬម្ចាស់វត្ថុតាង និងត្រូវចុះហត្ថលេខាលើ កំណត់ហេតុដកយកសំណាក។

ការដកយកសំណាកដែលជាកម្មវត្ថុ នៃការត្រួតពិនិត្យ ឬជាវត្ថុតាងនៃអំពើល្មើស ត្រូវអនុវត្តតាមបទប្បញ្ញត្តិជាធរមាន។

សំណាកដែលជាកម្មវត្ថុ នៃការត្រួតពិនិត្យ ឬជាវត្ថុតាងនៃអំពើល្មើស ត្រូវដាក់ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់អគ្គាធិការដ្ឋាន ឬតុលាការមានសមត្ថកិច្ចស្របតាមបទប្បញ្ញត្តិជាធរមាន។

លទ្ធផលវិភាគសំណាក ត្រូវបញ្ជូនទៅអគ្គាធិការដ្ឋាន សម្រាប់ភ្ជាប់ជាមួយសំណុំរឿងបទល្មើសដើម្បីបញ្ជូនទៅតុលាការមានសមត្ថកិច្ចស្របតាមបទប្បញ្ញត្តិជាធរមាន។

**ប្រការ ២៣..**

វត្ថុតាងនៃអំពើល្មើសដែលត្រូវចាប់យកក្នុងប្រតិបត្តិការអធិការកិច្ច ត្រូវរក្សាទុកក្នុងបន្ទប់ ឬឃ្លាំងដែលជានាសន្តិសុខ និងសុវត្ថិភាព គំនរវត្ថុតាងត្រូវបិទស្លាកបោះត្រា ឬគូសខ្វែងសម្គាល់សោរទ្វារឃ្លាំងរក្សា វត្ថុតាង ត្រូវបិទភ្ជិតដោយក្រដាសសុវត្ថិភាពដែលហាមឃាត់ការប៉ះពាល់រហូតដល់ករណីអំពើល្មើស ត្រូវបានដោះស្រាយចប់តាមនីតិវិធី ឬតាមរយៈការអនុវត្តសាលក្រម ឬសាលដីកាស្ថាពររបស់តុលាការ។

ក្នុងករណីម្ចាស់វត្ថុតាង នៃបទល្មើសមិនត្រូវបានស្គាល់អត្តសញ្ញាណអគ្គាធិការដ្ឋានត្រូវចេញសេចក្តីជូនដំណឹងរកបុគ្គលដែលប្រព្រឹត្តអំពើល្មើស ឬម្ចាស់វត្ថុតាងនៃអំពើល្មើស ដើម្បីចូលខ្លួនមកដោះស្រាយតាមនីតិវិធីជាធរមានក្នុងរយៈពេលមិនលើសពី៣០ (សាមសិប) ថ្ងៃគិតចាប់ពីថ្ងៃធ្វើអធិការកិច្ច និងចាប់យកវត្ថុតាងនោះ។ ការមិនចូលខ្លួនរបស់ម្ចាស់វត្ថុតាងតាមកាលកំណត់ វត្ថុតាងត្រូវបញ្ជូនទៅតុលាការតាមនីតិវិធីច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ ២៤..**

ការឆែកឆេរ ការឃាត់ខ្លួនជនសង្ស័យ ការចាត់វិធានការលើវត្ថុតាង នៃបទល្មើស និងប្រតិបត្តិការពាក់ព័ន្ធ



២ ৮

បទល្មើសព្រហ្មទណ្ឌផ្សេងទៀត ត្រូវអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាជាធរមាន។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**ប្រការ ២៥.**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ២៦.**

ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល អគ្គាធិការដ្ឋាន អគ្គនាយកដ្ឋានប្រៃសណីយ៍និងទូរគមនាគមន៍ វិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន អគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន នាយកដ្ឋានសវនកម្មផ្ទៃក្នុង គ្រប់មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ និងអង្គភាពក្រោមឱវាទក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ទាំងអស់ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៧រោចខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែមេសា ឆ្នាំ២០១៩

រដ្ឋមន្ត្រី

**ត្រាំ អ៊ីវតឹក**

កន្លែងទទួល៖

-ទីស្ដីការគណៈរដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី

-សាលារាជធានី ខេត្ត

«ដើម្បីជូនជ្រាប»

-ដូចប្រការ២៦ «ដើម្បីអនុវត្ត»

-រាជកិច្ច

-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

លេខ.........................បទ..........................

**ឧបសម្ព័ន្ធ**

**គម្រូនៃសេចក្តីជូនដំណឹង**

**ស្តីពីការធ្វើអធិការកិច្ចវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន**

**អគ្គាធិការដ្ឋាន នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**

-បានឃើញព្រះរាជក្រមលេខនស/រកម/១២១៥/០១៧ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ប្រកាសឱ្យប្រើច្បាប់ស្តីពីទូរគមនាគមន៍

-បានឃើញប្រកាសលេខ.......................................ស្តីពីបែបបទ និងនីតិវិធី នៃការធ្វើអធិការកិច្ចលើវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

**ជម្រាបមក**

លោក លោកស្រីឈ្មោះ.......................ភេទ ..............តួនាទី.............................. នៃក្រុមហ៊ុនឈ្មោះ........................................................................................................................ស្ថិតនៅទីតាំងផ្ទះលេខ..........................ផ្លូវ...........................ភូមិ..................................ឃុំ/សង្កាត់.................................... ស្រុក/ខណ្ឌ...........................................រាជធានី/ខេត្ត..................................ជ្រាបថា តាមលិខិតបញ្ជាបេសកកម្មលេខ..................................បទ ចុះថ្ងៃទី...............................ខែ ..................ឆ្នាំ.................. ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានចាត់តាំងគណៈប្រតិភូអធិការកិច្ច ដើម្បីធ្វើអធិការកិច្ចលើប្រតិបត្តិការទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានលើក្រុមហ៊ុន/អង្គភាពអាជីវកម្មរបស់លោក លោកស្រី ចាប់ពីថ្ងៃទី....................ខែ........ ឆ្នាំ............រហូតចប់ភារកិច្ច។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោក លោកស្រី** ជ្រាបជាព័ត៌មាន និងចូលរួមសហការល្អដល់ក្រុមការងារអធិការកិច្ច ដើម្បីឱ្យការងារអធិការកិច្ចមានដំណើរការរលូន និងទទួលបានប្រសិទ្ធភាពខ្ពស់។

សូម **លោក លោកស្រី** ទទួលនូវការរាប់អានពីខ្ញុំ៕

ថ្ងៃ.......................ខែ................ឆ្នាំ...........ព.ស២៥៦...

រាជធានីភ្នំពេញថ្ងៃទី..............ខែ................ឆ្នាំ២០.......

**អគ្គាធិការ**